01739744

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

# គម្រោងបញ្ចប់ផែនការ

# ខែ កក្កដា ឆ្នាំ ២០១៤ (កំណែលើកទី១)

## សេចក្តីសង្ខេប


I. **សេចក្តីផ្តើម** ........ 3

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** ........ 9

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** ........ 11

IV. **ផែនការបញ្ចប់សវនាការ** ........ 13

ក. សំណុំរឿង០០២/០១ ........ 14

ខ. សំណុំរឿង០០២/០២ ........ 15

គ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២ ........ 18

ឃ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ ........ 19

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** ........ 19

VI. **សេចក្តីសន្និដ្ឋាន** ........ 21


ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗផង។

# សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) បានរៀបចំឡើងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាបច្ចុប្បន្នភាពប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការដែលថ្មីៗនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤។

ចាប់តាំងពីកំណែទី១នៃការបញ្ចប់ផែនការនេះអង្គជំនុំជម្រះវិសាមញ្ញបានសម្រេចនូវព្រឹត្តិការណ៍សំខាន់មួយ ពោលគឺការចេញសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង០០២/០២។ ព្រឹត្តិការណ៍ដ៏សំខាន់មួយទៀតគឺការចេញសាលក្រមក្នុងសំណុំរឿងសំណុំរឿង០០២/០១ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។ សវនាការបឋមបន្ថែមក្នុងសំណុំរឿងសំណុំរឿង០០២/០២ ត្រូវបានកំណត់សម្រាប់ធ្វើឡើងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤។

ពេលវេលាកំណត់សម្រាប់ការចេញសាលក្រមក្នុងសំណុំរឿងសំណុំរឿង០០២/០១ និងថ្ងៃកំណត់ដាក់បណ្តឹងឧទ្ធរណ៍ ប្រសិនបើមាន ត្រូវបានលៃលកដោយអនុលោមទៅតាមដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូង។

គម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីការប្រែប្រួលនានាលើតារាងពេលវេលាតាមលំដាប់លំដោយទាក់ទិននឹងសំណុំរឿង០០៣ និង ០០៤។ តារាងពេលវេលានេះត្រូវបានកែសម្រួលដោយផ្អែកលើតម្រូវការក្នុងការស៊ើបអង្កេតបទចោទប្រកាន់បន្ថែមពាក់ព័ន្ធនឹងបទល្មើសយេនឌ័រ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលដាក់ជូនសហចៅក្រមស៊ើបអង្កេត នៅខែមេសា ឆ្នាំ២០១៤។ តារាងពេលវេលាបឋមដែលបានគ្រោងទុក ក៏ទទួលផលប៉ះពាល់ ដោយសារការថយ និងការកើនបុគ្គលិកនៅការិយាល័យសហចៅក្រមស៊ើបអង្កេតមានកម្រិតខ្ពស់ពេក ។

01739746

## I. សេចក្ដីផ្ដើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្ដើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្ដី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។ នៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ២០០៣ អគ្គលេខាធិការ ដំបូងឡើយបានបង្ហាញថា អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលបីឆ្នាំដើម្បីបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ “នៅពេលដែលការិយាល័យរបស់សហព្រះរាជអាជ្ញា បានចាប់ផ្ដើមប្រតិបត្តិការរបស់ខ្លួន”[2]។ តារាងកំណត់ពេលវេលាត្រូវបានកែប្រែចាប់តាំងពីពេលនោះមក ហើយអគ្គលេខាធិការបានជូនដំណឹងជាផ្លូវការដល់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែតុលា ឆ្នាំ២០១៣ថា តារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ “មានគម្រោងសកម្មភាពតុលាការរហូតដល់ឆ្នាំ២០១៨ និងអាចបន្តហួសពីពេលវេលាកំណត់នេះទៅទៀត”[3]។

២ គម្រោងបញ្ចប់ផែនការនេះ បានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក ក្នុងបរិបទនៃសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់ អ.វ.ត.ក ឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់[4] ដោយមានផែនទីបង្ហាញផ្លូវ

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] របាយការណ៍របស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះខ្មែរក្រហម ឯកសារ A/57/769 កថាខណ្ឌ៥៦។

[3] សំណើសុំថវិកាជំនួយផ្ដល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ A/68/532 កថាខណ្ឌ៣៨។

[4] នៅក្នុងសេចក្ដីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប បានស្នើឲ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើហិរញ្ញកិច្ចរបស់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្ដីសម្រេចលេខ A/RES/68/247B ដែលអនុម័ត

01739747

ច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក ដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អ.វ.ត.ក គិតទុកជាមុនថានៅពេលខាងមុខខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី១ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដែលចាំបាច់នានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤។

៣ ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងទាំងបីដែលកំពុងរង់ចាំនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក អាចនឹងបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។

៤ អង្គជំនុំជម្រះវិសាមញ្ញ បានបញ្ចប់ជាស្ថាពរនូវកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅឌុច នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។ កាំង ហ្កេកអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត និងត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីអនុវត្តទោសដែលនៅសល់ ។

៥ បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង០០២ ដែលជាការជំនុំជម្រះរួមលើ ខៀវ សំផន និង នួន ជា។ ជនជាប់ចោទទីបី ឈ្មោះ អៀង សារី បានទទួលមរណភាពកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ហើយកិច្ចដំណើរការនីតិវិធីលើរូបគាត់ ត្រូវបានបញ្ចប់នៅថ្ងៃនោះផងដែរ។ ជនជាប់ចោទទីបួន ឈ្មោះ អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងសវនាការ ដោយសារតែស្ថានភាពជំងឺវង្វេងស្មារតីកាន់តែធ្ងន់ធ្ងរ ហើយកិច្ចនីតិវិធីលើរូបគាត់បច្ចុប្បន្ននេះត្រូវបានព្យួរតាមរយៈការផ្អាកកិច្ចនីតិវិធីជាផ្លូវការ។ បច្ចុប្បន្នគាត់ស្ថិតនៅក្រោមការត្រួត

ដោយមហាសន្និបាត អ.ស.ប នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤។ "កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥" B, I, កថាខណ្ឌទី៨។

01739748

ពិនិត្យរបស់តុលាការ។ គាត់មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីប្រទេសកម្ពុជា ដោយគ្មានការអនុញ្ញាត ពីអង្គជំនុំជម្រះសាលាដំបូង គាត់មិនអាចផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅដោយមិនជូនដំណឹងជាមុន នោះទេ ហើយអាណាព្យាបាលស្របច្បាប់របស់គាត់ ត្រូវផ្តល់របាយការណ៍ប្រចាំខែដើម្បីបញ្ជាក់អំពី ការអនុវត្តលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ អៀង ធីរិទ្ធ ក៏ត្រូវទទួលបានការត្រួតពិនិត្យ ផ្នែកវេជ្ជសាស្ត្រពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃថាតើមានការប្រែប្រួលណាមួយទៅលើសមត្ថភាព បញ្ញាស្មារតី ដែលអាចប៉ះពាល់ដល់សម្បទារបស់គាត់ក្នុងការចូលរួមសវនាការផងដែរ។

៦ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង០០២ ទៅជាសវនាការតូចៗចំនួនពីរ ឬច្រើនបន្ត ទៀត។ ការបង្ហាញភ័ស្តុតាងនៅក្នុងសវនាការដំណាក់កាលទីមួយ ដែល អ.វ.ត.ក កំណត់ឈ្មោះ សំណុំរឿងថា សំណុំរឿង០០២/០១ ត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ និងសេចក្តី សន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល បានបញ្ចប់កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។ អង្គជំនុំជម្រះ នឹងចេញសាលក្រមនៃការជំនុំជម្រះនេះ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។ ទន្ទឹមពេលនៃដំណើរ ការព្រាងសាលក្រមនេះដែរ អង្គជំនុំជម្រះសាលាដំបូង ក៏រៀបចំការកិច្ចនីតិវិធីទាក់ ទិននឹងការជំនុំ ជម្រះបន្ទាប់ទៀត គឺសំណុំរឿង០០២/០២ ដែលនឹងត្រូវផ្តោតលើការចោទប្រកាន់មួយចំនួនទៅលើ ជនជាប់ចោទសេសសល់ពីររូបទៀត។ សវនាការបឋមនៃការជំនុំជម្រះមួយនៅក្នុងសវនាការទីពីរ គ្រោងនឹងចាប់ផ្តើមនៅនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ អាស្រ័យទៅលើការវិវត្តនៃ ការរៀបចំកិច្ច ដំណើរការនីតិវិធីដែលនៅសល់។ សវនាការលើភ័ស្តុតាងរំពឹងថានឹងចាប់ផ្តើមនៅ ត្រីមាសចុងក្រោយ នៃឆ្នាំ២០១៤។

៧ សំណុំរឿង០០៣ និង ០០៤ បច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត។ សហចៅ ក្រម ស៊ើបអង្កេតអន្តរជាតិ កំពុងស៊ើបអង្កេតសំណុំរឿងទាំងពីរនេះយ៉ាងសកម្ម ដែលពាក់ព័ន្ធនឹងការចោទ ប្រកាន់លើជនសង្ស័យចំនួនប្រាំរូប[5]។ គ្មានជនសង្ស័យណាម្នាក់ត្រូវបានចាប់ខ្លួន ឬចោទប្រកាន់ជាផ្លូវ ការនោះទេ ហើយអត្តសញ្ញាណរបស់ពួកគេ នៅតែរក្សាជាសម្ងាត់។ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីសន្និដ្ឋានបន្ថែមមួយ ដែលស្នើជា ផ្លូវការឲ្យសហចៅក្រម

---

[5] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។

ស៊ើបអង្កេតពង្រីកកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ ដើម្បីបញ្ចូលបទចោទពាក់ ព័ន្ធនឹងបទល្មើសផ្លូវភេទនិងឃាតកម្ម[6]។

៨ មានការរំពឹងថា សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ អាចនឹងចេញនៅត្រីមាសទី១នៃឆ្នាំ២០១៥ ហើយសេចក្តីសម្រេចមួយ ក្នុងទម្រង់ជាដីកាដំណោះស្រាយ ថាតើនឹងត្រូវចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណានោះ នឹងចេញនៅត្រីមាសទី៣ ឆ្នាំ២០១៥។

៩ ដោយហេតុថាមានការខុសប្លែកគ្នានៃស្ថានភាពស៊ើបអង្កេតប្រឆាំងនឹងជនសង្ស័យបីនាក់ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងតែពិចារណាលើជម្រើសចំនួន២៖ ក) សំណុំរឿង០០៤ អាចនឹងត្រូវបំបែក ដែលក្នុងករណីនេះ សេចក្តីជូនដំណឹងចំនួន២ អំពីការបញ្ចប់កិច្ចស៊ើបសួរអាចនឹងចេញនៅក្នុង ត្រីមាសទី១ នៃឆ្នាំ២០១៥ ហើយសេក្តីជូនដំណឹងទី៣ នឹងចេញនៅត្រីមាសទី២ ខ) ជម្រើសម្យ៉ាងទៀត សំណុំរឿង០០៤អាចស្ថិតនៅក្នុងទម្រង់ដដែល ដែលក្នុងករណីនេះ កិច្ចស៊ើបសួរអាចបញ្ចប់នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១៥។ ប្រសិនបើសំណុំរឿង០០៤ ត្រូវបានបំបែក គឺមានការប៉ាន់ស្មានថាដីកាដំណោះស្រាយ អាចចេញនៅក្នុងត្រីមាសទី២ ត្រីមាសទី៣ និង ត្រីមាសទី៤ ឆ្នាំ២០១៥។ ប្រសិនបើសំណុំរឿង០០៤ មិនត្រូវបានបំបែក មានការប៉ាន់ស្មានថា សេចក្តីសម្រេចមួយនឹងចេញនៅ ត្រីមាសទី៤ ឆ្នាំ២០១៥ នៅក្នុងទម្រង់នៃដីកាដំណោះស្រាយ ថាតើនឹងត្រូវចោទប្រកាន់ ហើយបញ្ជូនទៅជម្រះចំពោះជនសង្ស័យណាមួយ(ឬជនសង្ស័យណាខ្លះ) ។

១០ តារាងកំណត់ពេលវេលាសម្រាប់សំណុំរឿង០០៣ និង ០០៤ ដែលលើកឡើងនៅក្នុងគម្រោងថវិកាដែលបានអនុម័តរួចហើយសម្រាប់ឆ្នាំ២០១៤-២០១៥ សម្រាប់ អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានកែប្រែដោយសាកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការបំពេញកិច្ចស៊ើបសួរបន្ថែមអនុលោមតាមសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើបទល្មើសឃាតកម្ម ក្នុងសំណុំរឿង០០៤។ ការចោទប្រកាន់រួមមានអាពាហ៍ពិពាហ៍ដោយបង្ខំ រំលោភសេពសន្ថវៈ និង អំពើហិង្សាឃាតកម្ម ក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនោះរួមមានដូចជា ក្នុងករណីស្ត្រីត្រូវបានរំលោភមុនពេលសម្លាប់ និងស្ត្រីដែលបានរាយការណ៍អំពីការរំលោភសេពសន្ថវៈនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យក្រោយមក ក៏ត្រូវបាន

[6] សេចក្តីថ្លែងការរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងសំណុំរឿង០០៤ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ (http://www.eccc.gov.kh/sites/default/files/media/ECCC%20OCP%2024%20Apr%202014%20(En).pdf)

01739750

យកទៅសម្លាប់ផងដែរ។ តារាងកំណត់ពេលវេលាសម្រាប់សំណុំរឿង០០៣ និង ០០៤ ក៏ត្រូវរងផលប៉ះពាល់ផងដែរដោយសាការចាកចេញយ៉ាងច្រើនដែលមិនបានគិតដល់ របស់បុគ្គលិកពីការិយាល័យសហចៅក្រមស៊ើបអង្កេតចាប់តាំងពីការដាក់ឲ្យអនុម័តនូវគម្រោងថវិកាចុងក្រោយ។ ផលប៉ះពាល់នេះ និងពេលវេលាដែលត្រូវការក្នុងការជួលបុគ្គលិកដែលមានគុណវឌ្ឍិមកជំនួស និងបណ្តុះបណ្តាលអំពីប្រតិបត្តិការក្នុងបរិយាកាសនៃនីតិវិធីដែលមានតែមួយបែបនេះ បានពន្យឺតដល់ដំណើរការស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤។

១១ សហព្រះរាជអាជ្ញា បានលើកឡើងជាសាធារណៈថា បន្ទាប់ពីសំណុំរឿង០០៣ និង០០៤ នឹងលែងមានសំណុំរឿងបន្ថែមទៀតទេ[7]។ ចំនួនសំណុំរឿង ដែលមានបច្ចុប្បន្នគឺជាចំនួនសំណុំរឿងសរុបដែល នឹងត្រូវដោះស្រាយដោយ អ.វ.ត.ក។

១២ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញ មានគ្រោងការសំខាន់ចំនួន១៧សម្រាប់សំណុំរឿងចំនួនបីដែលនៅសេសសល់។ គ្រោងការសំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២[8] និងការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០១(នឹងចេញនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤)

(ii) ពេលវេលាកំណត់នៃដាក់បណ្តឹងសាទុកប្រឆាំងនឹងសាលក្រម នៅក្នុងសំណុំរឿង០០២/០១ (នៅត្រីមាសទីបួន ឆ្នាំ២០១៤)

(iii) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ប្រសិនបើមាន(ត្រីមាសទីមួយ ឆ្នាំ២០១៦)

[7] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf) និង សេចក្តីសន្និដ្ឋានជាសាធារណៈរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf)។

[8] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែមេសា ឆ្នាំ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

(iv) ការបើកសវនាការបឋមបន្ថែមមួយទៀតក្នុងសំណុំរឿង ០០២/០២ (នឹងធ្វើឡើងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤)

(v) ការចាប់ផ្តើមសវនាការលើអង្គសេចក្តី/ភ័ស្តុតាង ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួនក្នុង ឆ្នាំ២០១៤)

(vi) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភ័ស្តុតាង ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៦)

(vii) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៦)

(viii) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៧)

(ix) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៧) និង

(x) ការចេញសាលដីកាលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០២ ប្រសិនបើមានបណ្តឹងសាទុក្ខ (ត្រីមាសទីពីរ ឆ្នាំ២០១៩)

១៣ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេត ដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ នឹងបណ្តឹងសាទុក្ខ[9]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលនៅសេសសល់គឺៈ

[9] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី២៨ខាងក្រោម ដោយសាស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។ នៅក្នុងករណីដែលរឿងក្តីនេះត្រូវបញ្ជូនទៅជំនុំជម្រះ គ្រោងការនៃសវនាការលើអង្គសេចក្តីគឺអាចដូចទៅនឹងប្រការដែលមានចែងនៅក្នុងកថាខណ្ឌទី៩(v) តាមរយៈ(xi) ខាងលើទាក់ទិននឹងសំណុំរឿង០០២/០២។

(xi) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់មកពីភាគីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងសំណើសុំបំពេញកិច្ចស៊ើបសួរពីភាគី និង បណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចទាក់ទិននឹងនីតិវិធី។

(xii) ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ(ក្នុងសំណុំរឿង០០៣ នៅត្រីមាសទីមួយ ឆ្នាំ២០១៥)

(xiii) សេចក្តីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ (ត្រីមាសទីមួយឬទី២ ឆ្នាំ២០១៥)

(xiv) សេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និង/ឬ សហចៅក្រមស៊ើបអង្កេត (ត្រីមាសទីពីរ ឆ្នាំ២០១៥) ។

(xv) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទីបី ឆ្នាំ២០១៥)។

(xvi) ការចេញដីកាដំណោះស្រាយ(១ឬច្រើន)ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី(អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែកឬអត់ នៅត្រីមាសទីពីរ ទីបី ឬទីបួន ឆ្នាំ២០១៥)។

(xvii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយ (ត្រីមាសទីមួយ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៣ និង ត្រីមាសទីពីរ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៤)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១៤ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ អនុសាសន៍របស់មហាសន្និបាតទៅលើឧបត្ថម្ភធនចំនួន ១៥,៥ លានដុល្លារសម្រាប់ភាគីអន្តរជាតិ នៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកាសម្រាប់ឆ្នាំ២០១៤។

ការអភិវឌ្ឍជាវិជ្ជាមានមួយទៀតគឺការបង្កើនវិភាគទានពីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើការកៀរគរថវិកា។ជាការសំខាន់គឺត្រូវមានការកៀរគរថវិកាបន្ថែមដើម្បីធ្វើឲ្យមានស្ថិរភាពដល់ភាគីជាតិនៃ អ.វ.ត.ក។

១៥ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះនិងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុនៅតែបន្ត យើងនឹងចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១៦ ការប៉ាន់ស្មានលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និង ការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ សន្មត់ថាសកម្មភាពទាំងអស់ កំពុងត្រូវបានធ្វើឡើងដំណាលៗគ្នា។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ក៏ដូចជាសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី នឹងចូលពាក់ព័ន្ធទាំងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ និងការជំនុំជម្រះក្តីសំណុំរឿង០០២/០២ នៅពេលទន្ទឹមគ្នា។ សហព្រះរាជអាជ្ញានឹងចូលពាក់ព័ន្ធនៅក្នុងសំណុំរឿងទាំងនេះដែរ ហើយការស៊ើបអង្កេត និងការរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់សម្រាប់សំណុំរឿង ០០៣ និង ០០៤។ លទ្ធភាពនៃការអនុវត្តសកម្មភាពទាំងនេះគឺអាស្រ័យលើការចំនួនបុគ្គលិកគ្រប់គ្រាន់ក្នុងពេលទន្ទឹមគ្នា។

១៧ សហព្រះរាជអាជ្ញាបានស្នើឲ្យមានការកែប្រែវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីអនុញ្ញាតឲ្យកិច្ចស៊ើបសួរបន្តរហូតចប់ចុងចប់ដើមដោយមិនបាច់មានការស៊ើបអង្កេតលើទីតាំងប្រព្រឹត្តបទល្មើសទាំងអស់នោះទេ ល្គឹកណាទីតាំងប្រព្រឹត្តបទល្មើសដែលត្រូវបានជ្រើសរើស គឺជាតំណាងបទចោទប្រកាន់ និង ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យដែលបានចោទឡើង។ ប្រសិនបើកិច្ចប្រជុំចៅក្រមពេញអង្គអនុម័តលើសំណើនេះ គេរំពឹងថាវិសោធនកម្មលើវិធានផ្ទៃក្នុងអាចពន្លឿនការបញ្ចប់កិច្ចស៊ើបសួរបានឆាប់រហ័ស។

១៨ ដើម្បីបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបីនាក់ និងបន្ថែមម្នាក់ទៀតតាមក្រោយ ដើម្បីចុះ

ធ្វើកំណត់ហេតុស្តាប់ចម្លើយ ហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ នឹងជំរុញឲ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីបង្កើនធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញដែលមិនយកប្រាក់កម្រៃ និងកម្មសិក្សាការីបន្ថែមទៀត ដើម្បីបង្កើនផលិតផលនៃកិច្ចស៊ើបសួរ។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៩ តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេត ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវស្តាប់សក្ខីកម្ម ចំនួនបេសកម្មចុះដល់ទីកន្លែងដែលតម្រូវឲ្យមាន បុគ្គលិកមានគុណវុឌ្ឍិ ការបង្អាក់ជាក់ស្តែងក្នុងការបំពេញកិច្ចស៊ើបសួរ ចំនួនញត្តិដែលដាក់ដោយភាគីនានា ថិរវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ភាគីនានា និងការពិចារណាពាក់ព័ន្ធនានា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ អាចផ្អែកលើបទពិសោធន៍កន្លងទៅទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងក្នុងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

២០ វាមានលក្ខណៈសំខាន់ក្នុងការរំឭកដោយសង្ខេបអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឲ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ។ ភាគីនានាអាចស្នើសុំសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន។ ការបដិសេធមិនពិចារណាលើសំណើសុំអាចនឹងត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

២១ នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់។ ភាគីមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឲ្យបំពេញកិច្ច

ស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ នៅពេលដែលរយៈពេលនេះ បានផុតកំណត់, ត្រូវបានបោះបង់ចោល ឬបណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និងបង្វិលសំណុំរឿងឲ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល៤៥ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល៣ខែនៅក្នុងរឿងក្តីផ្សេងទៀត។ លើកលែងតែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។ សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្តល់នូវសិទ្ធិឲ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២២ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្តើមដំណើរការក្រោយពីការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅខែកញ្ញាឆ្នាំ២០០៩។ ដោយអនុលោមតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក សហចៅ ក្រមស៊ើបអង្កេត បានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែជ្រើសរើសវិធីសាស្ត្ររៀងៗខ្លួននៅក្នុងសំណុំរឿងទាំងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មលើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមូលដ្ឋានបទល្មើសចំនួនជាង១០

ផ្សេងៗពីគ្នាក្នុងសំណុំរឿង០០៣ និង មូលដ្ឋានបទល្មើសចំនួន៥៥ក្នុងសំណុំរឿង ០០៤។ ចាប់តាំងពីសហចៅក្រមអន្តរជាតិបច្ចុប្បន្ន ចាប់ផ្តើមបំពេញភារកិច្ចនៅខែតុលា ឆ្នាំ២០១២ មក មានការបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុ ចំនួនជាង៧០លើក និង ធ្វើកិច្ចសម្ភាសន៍ បានចំនួនជាង២៥០លើក។ ពេលវេលាស្មានទុកដ៏សុក្រឹតដែល អាចផ្តល់ជូនបាននៅខណៈនេះ គឺ

(i) កិច្ចស៊ើបសួរក្នុងសំណុំ រឿង០០៣ នឹងត្រូវបញ្ចប់ ត្រឹមចុងត្រីមាសទីមួយ ឆ្នាំ ២០១៥

(ii) កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ នឹងត្រូវបញ្ចប់នៅត្រីមាសទីមួយ ឬទីពីរឆ្នាំ២០១៥ អាស្រ័យលើថាតើសំណុំរឿងនេះនឹងត្រូវបំបែក ឬអត់

(iii) ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ នឹង ត្រូវចេញនៅ ត្រីមាសទីបី ឆ្នាំ ២០១៥

(iv) ដីកាដំណោះស្រាយ(មួយឬច្រើន)ក្នុងសំណុំរឿង០០៤ នឹងត្រូវចេញនៅត្រីមាសទីពីរ ទីបី ឬទីបួន ឆ្នាំ២០១៥ អាស្រ័យលើថាតើសំណុំរឿងនេះនឹងត្រូវបំបែកឬអត់ និង

(v) រាល់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយនឹងត្រូវសម្រេចសេចក្តីដោយអង្គបុរេជំនុំជម្រះនៅ ត្រីមាសទីមួយ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៣ និង ត្រីមាសទីពីរ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៤។

## IV. ផែនការបញ្ចប់សវនាការ

២៣ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា: លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សីដែលត្រូវកោះហៅ និងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការគឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

២៤ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការ ចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលា ដំបូងត្រូវពិចារណាទៅលើបញ្ជីសាក្សីសក្ខីកម្ម និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីនឹងចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហ ព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភ័ស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះនឹងស្តាប់នូវការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្តី។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះនឹងសម្រេចទៅលើទោសដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

## ក. សំណុំរឿង០០២/០១

២៥ សវនាការបឋមក្នុងសំណុំរឿង០០២ ប្រព្រឹត្តទៅចាប់ពី ថ្ងៃទី២៧ រហូតដល់ថ្ងៃ៣០ ខែមិថុនា ឆ្នាំ ២០១១។ ក្នុងខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកនូវបទចោទក្នុងសំណុំរឿង០០២ ទៅជាសវនាការចំនួនពីរឬច្រើន អនុលោមទៅតាមវិធានផ្ទៃក្នុង ដែលនឹងត្រូវវិនិច្ឆ័យដោយអង្គជំនុំជម្រះទៅតាមលំដាប់លំដោយតាមការយល់ឃើញថាសមស្រប។ បទចោទនៅក្នុងសវនាការដំបូង (ក្នុងសំណុំរឿង០០២/០១) ផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ទាក់ទិននឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងទីប្រជុំជន ព្រមទាំង ការសម្លាប់ទាហាន លន់ នល់ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ភ្លាមៗក្រោយពេលខ្មែរក្រហម ឡើងកាន់អំណាច ក្នុងខែមេសា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះក៏បានស្តាប់នូវការបង្ហាញភ័ស្តុតាងទាក់ទិននឹងប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា

របចនាសម្ព័ន្ធចាត់តាំងនៃកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទពាក់ព័ន្ធនឹងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងបទចោទទាំងអស់ក្នុងសំណុំរឿង០០២។

២៦ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១១។ សាក្សីចំនួន៥៨រូប ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១រូប និងអ្នកជំនាញចំនួន ៣រូប បានផ្តល់សក្ខីកម្មនៅអំឡុងពេលសវនាការ ហើយការបិទកិច្ចពិភាក្សាដេញដោលប្រព្រឹត្តទៅនៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣។ ដូច្នេះ ដំណើរការនីតិវិធីសវនាការទាំងមូលប្រព្រឹត្តទៅអស់រយៈពេល ២២២ថ្ងៃ ។ បច្ចុប្បន្ននេះអង្គជំនុំជម្រះសាលាដំបូង ចេញសាលក្រមលើអង្គសេចក្តីនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។

## ខ. សំណុំរឿង០០២/០២

២៧ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងការបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំងរឿង០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿងទីពី(០០២) សំណុំរឿង០០២/០២ គួរតែចាប់ផ្តើមកាន់តែឆាប់កាន់តែប្រសើរក្រោយ ពីការបិទកិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានសម្រេចថាវិសាលភាពនៃសំណុំរឿង០០២/០២ ជាតំណាងឲ្យដីកាបញ្ជូនទៅជំនុំជម្រះ ដូច្នេះ តុលាការកំពូលបង្គាប់ថាអង្គជំនុំជម្រះជាអបប្បរមាគួរតែបញ្ចូលបទចោទដែលពាក់ព័ន្ធឧក្រិដ្ឋកម្មប្រល័យ ពូជសាសន៍ មន្ទីរសន្តិសុខ ស២១ នៅភ្នំពេញ សហករណ៍ចំនួនមួយ និងការដ្ឋានចំនួនមួយ[10]។

២៨ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១១ និង ១២ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីត្រៀមលក្ខណៈសម្រាប់សវនាការបន្ទាប់នេះ។ ក្រោយពីកិច្ចប្រជុំនេះមក អង្គជំនុំជម្រះបានចេញនូវផែនការការងារលម្អិត ហើយអញ្ជើញភាគីឲ្យដាក់សារណាស្តីពីបទចោទដែលនឹងត្រូវបញ្ចូលទៅក្នុង

[10] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ (www.eccc.gov.kh/sites/default/files/documents/courtdoc/2013-07-23%2016:57/E284_4_7_EN.PDF)។

សំណុំរឿង០០២/០២ ។[11] សវនាការតទល់គ្នាបានធ្វើឡើងនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៤។ ក្នុងពេលសវនាការនេះ ភាគីបានធ្វើទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងសារណារបស់ខ្លួនអំពីវិសាលភាពនៃបទចោទ ក៏ដូចជាជំហររបស់ខ្លួនទៅលើសារណាបន្ថែមរបស់មេធាវីការពារក្តីមួយ (ខៀវ សំផន) ទាក់ទិននឹងអត្ថិភាពនៃឧបសគ្គតាមផ្លូវច្បាប់ចំពោះការចាប់ផ្តើមសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើបញ្ហាទាំងពីរនេះ មុនពេលកំណត់ ក្នុងខែមីនា ឆ្នាំ២០១៤ ដោយបដិសេធនូវសារណារបស់ក្រុមមេធាវីការពារក្តី។

២៩ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវសេចក្តីសម្រេចបំបែកសំណុំរឿងថ្មីមួយទៀត ដោយកំណត់វិសាលភាពក្នុងសំណុំរឿង០០២/០២។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទីតាំងបទល្មើសដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុបង្កើតបានជាមូលដ្ឋាននៃសំណុំរឿង០០២/០២៖ អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម (មិនរាប់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភ (ទូទាំងប្រទេស) ការបោសសម្អាតផ្ទៃក្នុង មន្ទីរសន្តិសុខ ស២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម សហករណ៍នៅត្រាំកក់ ការប្រព្រឹត្តមកលើពុទ្ធសាសនិក (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការដៅលើអតីតអ្នកមុខអ្នកការរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)[12]។ សេចក្តីសម្រេចបំបែកសំណុំរឿងនេះកំពុងជាប់បណ្តឹងសាទុក្ខនៅអង្គជំនុំជម្រះតុលាការកំពូល។

៣០ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទសម្រាប់សវនាការបឋមបន្ថែមទៀតក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ៣០-៣១ ខែកក្កដា ឆ្នាំ២០១៤។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះសាលាដំបូង

---

[11] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ (www.eccc.gov.kh/sites/default/files/documents/courtdoc/2014-01-02%2010:19/E301_5_EN.PDF)។

[12] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និង វិសាលភាពនៃសំណុំរឿង០០២/០២ (អបសដ) ឯកសារ E301/9/1 ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៣៦-៣៨។

នឹងលើកឡើងអំពីលំដាប់លំដោយនៃនីតិវិធីជំនុំជម្រះបន្ថែមទៅលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនលើវិសាលភាពនៃសំណុំរឿង០០២/០២ ហើយនឹងពិនិត្យមើលបញ្ជីសាក្សីសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលដាក់ដោយភាគី។ អង្គជំនុំជម្រះក៏នឹងលើកឡើងអំពីការកំណត់ជាក់លាក់ថែមទៀតទៅលើសំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្ថានភាពនៃអញ្ញត្រកម្ម និងបញ្ហាច្បាប់នានាពាក់ព័ន្ធនឹងសំណុំរឿង០០២/០២។

៣១ ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការ គឺអាចស្មានទុកបានក្នុងសំណុំរឿង០០២/០២ តែនៅពេល (i) សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីចូលជាស្ថាពរបន្ថែមទៅលើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងអង្គជំនុំជម្រះតុលាការកំពូល (ii) ចំណែកឯចំនួន សាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ គឺមានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង ។ ការស្មានទុកពេលទាក់ទិននឹងសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថា សវនាការទីពីរនឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការទីមួយដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តាទាំងពីរនេះត្រូវបានកំណត់។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបន្ថែមផងដែរថា "ភស្តុតាងដែលដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ត្រូវយកជាមូលដ្ឋាន សម្រាប់សំណុំរឿង០០២/០២" ដោយមិនត្រូវការអនុវត្តនីតិវិធីជាផ្លូវការម្តងទៀតឡើយ នៅក្នុងការជំនុំជម្រះក្តីនាពេលខាងមុខនេះ[13]។ សេចក្តីសម្រេចនេះនឹងមានផលវិជ្ជមានចំពោះពេលវេលាដែលតម្រូវ ដើម្បីបញ្ចប់ការជំនុំជម្រះក្តីនេះ។

៣២ រយៈពេលនៃជំនុំជម្រះដែលស្មានទុកក៏នឹងត្រូវប៉ះពាល់ដោយសារការកំណត់សម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងតម្រូវការចាំបាច់ ក្នុងការកាត់បន្ថយចំនួនថ្ងៃសវនាការក្នុងមួយសប្តាហ៍ និងរយៈពេលនៃថ្ងៃមានសវនាការ ដោយសារស្ថានភាពសុខភាពរបស់ជនជាប់ចោទ។ ក្រុមមេធាវីការពារក្តីទាំងពីរក្រុមបានដាក់សារណាជាផ្លូវការរួចរាល់ហើយ ដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់អ្នកជំនាញវិជ្ជសាស្ត្រពិនិត្យសម្បទារបស់ជនជាប់ចោទនៅក្នុងអំឡុងសប្តាហ៍ចុងក្រោយនៃ

---

[13] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា"ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង០០២/០១ សម្រាប់សំណុំរឿង០០២/០២" (www.eccc.gov.kh/sites/default/files/documents/courtdoc/2014-02-07%2016:14/E302_5_EN.PDF)។

ខែមីនា ឆ្នាំ២០១៤។ ខណៈដែលជនជាប់ចោទបន្ទាប់មកត្រូវរកឃើញថាមានសម្បទាគ្រាប់គ្រាន់ក្នុងការចូលរួមសវនាការ ការវាយតម្លៃណាមួយបន្ថែមទៀតទៅលើស្ថានភាពសុខភាពរបស់ពួកគាត់អាចតម្រូវឱ្យមានការកែប្រែមួយទៅលើការកំណត់ពេលវេលាបើកសវនាការ។ នីតិវិធីបណ្តឹងសាទុក្ខណាមួយប្រឆាំងសាលក្រមសំណុំរឿងសំណុំរឿង០០២/០១ក៏អាចមានផលប៉ះពាល់ដល់ភាពទំនេររបស់ភាគីក្នុងការចូលរួមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ផងដែរ។

៣៣ ក្រោយពីចេញសាលក្រមក្នុងសំណុំរឿង០០២/០១ មក ភាគីខ្លះបានបង្ហាញថាខ្លួនអាចប្តឹងជំទាស់នឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ដោយហេតុថាឃើញលេចឡើងនូវការលំអៀង ដោយសារចៅក្រមដដែលកាត់សេចក្តីលើដំណាក់កាលទាំងពីរនៃសំណុំរឿង០០២។ ការប្តឹងបែបនេះអាចតម្រូវឱ្យមានការចាត់តាំងចៅក្រមបន្ថែមទៀតមកពីអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីបង្កើតនូវអង្គជំនុំជម្រះពិសេសមួយមានភារកិច្ចសេចក្តីសម្រេចលើការប្តឹងជំទាស់នេះ។ ការសម្រេចទៅលើបណ្តឹងជំទាស់នេះក៏អាចមានផលប៉ះពាល់ដល់ការកំណត់ពេលវេលាសម្រាប់សវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២ ផងដែរ។

៣៤ ផ្នែកលើកត្តាទាំងនេះ អង្គជំនុំជម្រះសាលាដំបូងកំពុងតែបំពេញកិច្ចការឆ្ពោះទៅចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅត្រីមាសចុងក្រោយនៃឆ្នាំ២០១៤។

## គ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២

៣៥ បន្ទាប់ពីសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង០០២/០២ កំពុងចូលជាស្ថាពរ ភាគីនានានឹងត្រូវបានផ្តល់ឱកាសឱ្យដាក់សារណាជូនអង្គជំនុំជម្រះសាលាដំបូងអំពីអង្គហេតុ និង/ឬបទចោទប្រកាន់នានា ដែលមិនបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២។ ក្របខណ្ឌគតិយុត្តដែលគ្រប់ដណ្តប់នីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ មិនមានចែងច្បាស់លាស់អំពីការទម្លាក់ការចោទប្រកាន់ ឬអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ យ៉ាងណាក៏ដោយអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ការដកចេញនូវបទចោទប្រកាន់ អាចត្រូវបានអនុញ្ញាតផ្អែកតាមយុត្តិសាស្ត្រអន្តរជាតិ "ដរាបណាបញ្ហាទាំងនេះត្រូវបានដោះស្រាយប្រកបដោយតម្លាភាពដោយធ្វើការពិចារណាទៅលើផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិដែលពាក់ព័ន្ធក្នុងការទទួលបានការ

01739762

ជំនុំជម្រះដោយយុត្តិធម៌ ដោយមានការព្រមព្រៀងពីសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូង"[14]។ អង្គជំនុំជម្រះសាលាដំបូងត្រូវការវាយតម្លៃវិសាលភាពនៃអំណាចទាំងនេះឲ្យបានច្បាស់ ដែលមានអានុភាពអនុវត្តចំពោះរឿងក្ដីនេះ។

## ឃ. សំណុំរឿង០០៣ និង សំណុំរឿង០០៤

៣៦ លុះត្រាតែមានសេចក្ដីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្ដីទាំងនេះបាន។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្ដឹងសាទុក្ខ

៣៧ ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ត្រូវតែញែកឲ្យបានច្បាស់អំពីដំណាក់កាលបណ្ដឹងសាទុក្ខ ដូចតទៅ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខក្នុងរយៈពេល៣០ ថ្ងៃក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមានបណ្ដឹងសាទុក្ខ ដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ ថ្ងៃទៀត ដើម្បីដាក់សេចក្ដីសុំប្ដឹងសាទុក្ខ។ ម្ចាស់បណ្ដឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្ដឹងសាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្ដឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល១០ថ្ងៃក្នុងការដាក់ចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្ដល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បី

[14] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/4/8 ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ ៦២ (www.eccc.gov.kh/sites/default/files/documents/courtdoc/2014-01-03%2012:17/E284_4_8_EN-2.PDF)។

រៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្តឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ សវនាការលើបណ្តឹងសាទុក្ខអាចត្រូវបានបង្គាប់ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួនរួចហើយ។ ដំណាក់កាលទីបី គឺ ការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្តឹងសាទុក្ខ។

៣៨ ការព្យាករណ៍ត្រឹមត្រូវមិនអាចធ្វើទៅបានទេក្នុងករណីគ្មានសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងរាល់ការចង្អុលបង្ហាញណាមួយទាក់ទិនថាតើភាគីមួយចំនួន ឬទាំងអស់ មានបំណងប្តឹងសាទុក្ខ ហើយបើមានបំណងមែន តើដល់កម្រិតណានោះ។ ហេតុដូច្នេះការព្យាករណ៍បច្ចុប្បន្ននេះគឺផ្អែកលើសេណារីយ៉ូនៃរឿងក្តីតាមសម្មតិកម្ម ដែលក្នុងនោះសំអាងហេតុទាំងអស់នៅក្នុងសាលក្រមសំណុំរឿង០០២/០១ ត្រូវបានប្តឹងសាទុក្ខដោយភាគីមួយ ឬច្រើន ក្នុងនោះរួមមានបណ្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអាចលើកឡើងនៅកំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ក៏ដូចជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានចោទឡើង។ ដោយពិចារណាទៅលើកាលកំណត់កាលបរិច្ឆេទដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក និងយុត្តិសាស្ត្រដែលទាក់ទិនសម្រាប់រឿងក្តីដែលមានទំហំ និងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា អាចនាំឲ្យមានការប៉ាន់ស្មានដ៏ត្រឹមត្រូវមួយនាពេលនេះគឺថា ក្នុងករណីដែលសាលក្រមក្នុងសំណុំរឿង ០០២/០១ ត្រូវបានបណ្តឹងសាទុក្ខតាមវិធីនេះ វានឹងត្រូវការពេល១៨ខែទើបចប់ពេញលេញ។ ៨ ទៅ ៩ ខែដំបូង នឹងទាក់ទិននឹងការរៀបចំដាក់សារណារបស់ភាគីទាំងអស់ បន្ទាប់មកគឺការរៀបចំសវនាការលើបណ្តឹងសាទុក្ខណាមួយនោះ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវការរយៈពេល៩ ទៅ១០ ខែទៀត ដើម្បីបញ្ចប់នូវការពិភាក្សាសម្រេច និងរៀបចំចេញសាលដីការបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។

៣៩ សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូច ជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករណ៍ស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្តឹងសាទុក្ខទីពីនឹងមានលក្ខណៈស្មុគស្មាញនិងត្រូវការពេលវេលាច្រើនដូចគ្នានឹងបណ្តឹងសាទុក្ខទី១ដែរ។ ជាងនេះទៀត គួរកត់សម្គាល់ថា កត្តាមួយចំនួន ដូចជាសំណើសុំពន្យារពេលក្នុងការដាក់សារណា ឬញត្តិ ដើម្បីស្នើដាក់ជូនភស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈ

ពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ហើយនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការ ក្រោយពេលមានការដាក់បណ្តឹងសាទុក្ខផងដែរ។

៤០ ជាងនេះទៅទៀត បណ្តឹងសាទុក្ខភ្លាមៗដែលអាចកើតមានចេញពីសំណុំរឿង០០២/០២ ត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់។ ផ្អែកលើបទពិសោធន៍ពីសំណុំរឿង០០២/០១ គិតជាមធ្យម រំពឹងថាមានបណ្តឹងសាទុក្ខភ្លាមៗចំនួនមួយក្នុងមួយខែ។ ប្រការនេះអាចធ្វើឱ្យមានតម្រូវការធនធានរបស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែធំឡើង ហើយប៉ះពាល់ដល់តារាងកំណត់ពេលវេលាសម្រាប់ការចេញសាលដីកាលើបណ្តឹងសាទុក្ខ។

## VI. សេចក្តីសន្និដ្ឋាន

សម្រាប់ឆ្នាំ ២០១៤ រំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួន៥៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០១ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ (ii) ពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ (iii) ការចេញសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង០០២/០២ (iv) ការបើកសវនាការបឋមក្នុងសំណុំរឿង០០២/០២ (v) ការចាប់ផ្តើមសវនាការលើអង្គសេចក្តី/ភ័ស្តុតាងក្នុង សំណុំរឿង ០០២/០២។

៤១ សម្រាប់ឆ្នាំ ២០១៥ កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២នឹងបន្តពេញរយៈពេលមួយឆ្នាំ ហើយមានការរំពឹងថានឹងសម្រេចបាននូវគ្រោងការថ្មីចំនួនបួនពោលគឺទាក់ទិននឹងសំណុំរឿង០០៣ និង ០០៤ (i) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ក្នុងសំណុំរឿង០០៣(ii)សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤។ (iii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីតែម្តង។ (iv) ការចេញដីកាដំណោះស្រាយមួយ(ច្រើន)ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៤២ សម្រាប់ឆ្នាំ២០១៦ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនបួន គឺ៖ (i) ការចេញសាលដីកាលើបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ (ii) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភ័ស្តុតាងក្នុង

សំណុំរឿង០០២/០២ (iii) ការបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលក្នុងសំណុំរឿង ០០២/០២ និង (iv) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង ០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីតុលាការ។ ក្នុងករណីដែលសំណុំរឿងណាមួយ ឬសំណុំរឿងទាំងពីរ ត្រូវបានបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះគឺអាចយកមកវាយតម្លៃបាន។

៤៣ សម្រាប់ឆ្នាំ ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនពីរ គឺ៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០២ និង (ii) ពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០២។

៤៤ ក្នុងអំឡុងឆ្នាំ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៤៥ សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនមួយ គឺ ៖ (i) ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៤៦ ការស្មានទុកនូវគ្រោងការនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជូនជាមួយនឹងផែនការនេះស្រាប់។

## តារាងកំណត់ពេលវេលាតាមការគ្រោងទុក ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗផង




(ក) សាលក្រម សំណុំរឿង០០២/០១

(ខ) កាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម សំណុំរឿង០០២/០១

(គ) សាលដីកា សំណុំរឿង០០២/០១




(ឃ) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីវិសាលភាពនៃសំណុំរឿង០០២/០២

(ង) សវនាការបឋម សំណុំរឿង០០២/០២

(ច) ការចាប់ផ្តើមសវនាការលើអង្គសេចក្តី សំណុំរឿង០០២/០២

(ឆ) ការបញ្ចប់សវនាការលើអង្គសេចក្តី សំណុំរឿង០០២/០២

(ជ) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង០០២/០២

(ឈ) សាលក្រម សំណុំរឿង០០២/០២

(ញ) កាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម សំណុំរឿង០០២/០២

(ដ) សាលដីកា សំណុំរឿង០០២/០២




(ឋ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ចំពោះសំណុំរឿង០០៤ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ឌ) ដីកាដំណោះស្រាយ កសចស។ ចំពោះសំណុំរឿង០០៤ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ឍ) សេចក្តីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ